# ស្ថានទូតអូស្ត្រាលី និង ក្រសួងមហាផ្ទៃ

## សេចក្តីប្រកាសព័ត៌មានរួម

## ប្រទេសអូស្ត្រាលីជួយគាំទ្រដើម្បីធ្វើអោយលក្ខខ័ណ្ឌពន្ធនាគារល្អប្រសើរ

ប៉ុស្តិ៍សុខភាពនិងរបងសុវត្ថិភាពថ្មីនៅមណ្ឌលអប់រំកែប្រែទី៣(មព) ក្នុងខេត្តកំពង់ចាមត្រូវបានសម្ពោធបើកឱ្យប្រើប្រាស់ក្រោម អធិបតីភាព ឯកឧត្តម **នុត សាវអាន** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងលោកស្រី **អាន្ជី ផាតែល** លេខាទី១ ទីភ្នាក់ងារអូស្ត្រាលីដើម្បីអភិវឌ្ឍន៍អន្តរជាតិ (AusAID)។

"បច្ចុប្បន្ននេះនៅប្រទេសកម្ពុជា មានអ្នកទោសសរុបចំនួន ១៣.000នាក់ ដែលកំពុងត្រូវបានឃុំឃាំងនៅក្នុងពន្ធនាគារដែលក្នុងនោះ ហេដ្ឋារចនាសម្ព័ន្ធបានសាងសង់សំរាប់ឃុំឃាំងបានតែ ៨.000នាក់ប៉ុណ្ណោះ។ ការវិនិយោគរួមគ្នានៅក្នុងការសាងសង់ហេដ្ឋារចនាសម្ព័ន្ធពន្ធនាគារដោយរដ្ឋាភិបាលអូស្ត្រាលី និងរាជរដ្ឋាភិបាលកម្ពុជា មានសារសំខាន់ក្នុងការគ្រប់គ្រង ពិរុទ្ធជន និង ទណ្ឌិត ក្នុងការធានាលក្ខខ័ណ្ឌសន្តិសុខ សុវត្ថិភាព និងប្រកបដោយមនុស្សធម៌ "។ នេះគឺជាគម្រោងហេដ្ឋារចនាសម្ព័ន្ធលើកទីមួយដែលបានសាងសង់បញ្ចប់នៅមណ្ឌលអប់រំកែប្រែទី៣ក្រោមជំនួយមូលនិធិក្នុងវិស័យពន្ធនាគារ ចំនួន ១.២៥0.000 ដុល្លាអូស្ត្រាលី តាមរយៈគម្រោងជំនួយផ្នែកព្រហ្មទណ្ឌ និង យុត្តិធម៌នៅកម្ពុជាដំណាក់កាលទី៣(CCJAPIII)" នេះជាប្រសាសន៍របស់លោកស្រី **អាន្ជី ផាតែល** លេខាទី១ ទីភ្នាក់ងារអូស្ត្រាលីដើម្បីអភិវឌ្ឍន៍អន្តរជាតិ ដែលបានថ្លែងក្នុងពិធីសម្ពោធ នាថ្ងៃទី ២៦ ខែ មិនា ។

ឯកឧត្តម **នុត សាវអាន** រដ្ឋលេខាធិកាក្រសួងមហាផ្ទៃ បានមានប្រសាសន៏ថា ប៉ុស្តិ៍សុខភាព និងរបងសុវត្ថិភាពថ្មីនេះបានរួមចំណែកដល់ការខិតខំក្នុងកម្មវិធីកំណែទម្រង់ដែលដឹកនាំដោយអគ្គនាយកដ្ឋានពន្ធនាគារ។ ការងារដែលបានសាងសង់នៅមណ្ឌលអប់រំកែប្រែទី៣ នឹងធ្វើអោយសុខភាពផ្លូវកាយ និងផ្លូវចិត្តរបស់ទណ្ឌិត មានលក្ខណៈល្អប្រសើរ។ ប៉ុស្តិ៍សុខភាពថ្មី និងការបំពាក់ឧបករណ៍បរិក្ខា អាចផ្តល់លទ្ធភាពសំរាប់ការថែទាំ និងព្យាបាលសុខភាពកំរិតបឋមនៅ

ក្នុងពន្ធនាគារ កាត់បន្ថយភាពឃឹតឃ៉ាវ ហានិភ័យសន្តិសុខ និងសោហ៊ុយចំណាយផ្សេងៗពាក់ព័ន្ធនឹងការដឹកជញ្ជូនទៅមន្ទីរពេទ្យ។ បច្ចុប្បន្ននេះ ទណ្ឌិតអាចត្រូវបានព្យាបាលដើម្បីបង្ការទប់ស្កាត់ការឆ្លងជំងឺនានា ដូចជាជំងឺរបេងជាដើម។ ការកែលំអរនិងសាងសង់របងសុវត្ថិភាព អាចផ្តល់លទ្ធភាពអោយទណ្ឌិតបានចេញមកក្រៅបន្ទប់ឃុំឃាំងជារៀងរាល់ថ្ងៃដែលធានាបាននូវការហាត់ប្រាណនិងខ្យល់អាកាសល្អ។

"កិច្ចសហប្រតិបត្តិការរវាងទីភ្នាក់ងារអូស្ត្រាលីដើម្បីអភិវឌ្ឍអន្តរជាតិ និង ក្រុមការងារសំណង់របស់អគ្គនាយកដ្ឋានពន្ធនាគារ បានរួមចំណែកយ៉ាងធំធេងក្នុងការរៀបចំបទដ្ឋានសាងសង់ហេដ្ឋារចនាសម្ព័ន្ធពន្ធនាគារអោយមានភាពល្អប្រសើរ "។ បទពិសោធន៍ដែលបានស្វែងយល់ពីពន្ធនាគារគំរូនៅក្នុងខេត្តកណ្តាលដែលបានសាងសង់ដោយជំនួយប្រទេសអូស្ត្រាលី នៅឆ្នាំ២០០៦ បានកំណត់ជាបទដ្ឋានគំរូមួយ សំរាប់សាងសង់ហេដ្ឋារចនាសម្ព័ន្ធពន្ធនាគារថ្មីនៅកម្ពុជា" ឯកឧត្តម **ហេង ហាក់** អគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធនាគារបានមានប្រសាសន៍ដូចនេះ។

ប្រទេសអូស្ត្រាលីបានផ្តល់ជំនួយគាំទ្រដល់កំណែទម្រង់ប្រព័ន្ធព្រហ្មទណ្ឌ និងយុត្តិធម៌នៅកម្ពុជាចាប់តាំងពីឆ្នាំ ១៩៩៧ ។ គម្រោងជំនួយផ្នែកព្រហ្មទណ្ឌនិងយុត្តិធម៌នៅកម្ពុជាដំណាក់កាលទី៣ (ឆ្នាំ២០០៧-២០១២) សហការជាមួយរាជរដ្ឋាភិបាលកម្ពុជា និង អង្គការក្រៅរដ្ឋាភិបាល ធានាអោយមាននូវការកែលម្អ វិស័យពន្ធនាគារ នគរបាល តុលាការ និង សកម្មភាពទប់ស្កាត់បទល្មើសនិងសុវត្ថិភាពសហគមន៍ នៅក្នុងបណ្តាខេត្តជាដៃគូទាំង០៦។

***ព័តមានបន្ថែមៈ***

កាលបរិច្ឆេទៈ ថ្ងៃទី ២៦ ខែ មិនា ឆ្នាំ ២០១០

ទីកន្លែងៈ មណ្ឌលអប់រំកែប្រែទី៣ (មស៣) ខេត្តកំពង់ចាម

ទំនាក់ទំនងព័តិមានៈ លោកស្រី **អាន្នី ផាតែល** ស្ថានទូតអូស្ត្រាលី ទូរស័ព្ទលេខៈ ០២៣ ២១៣ ៤៧០